# សមិទ្ធផលរបស់ក្រុមការងារបច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការនៃក្រសួងមុខងារសាធារណៈ

## ដោយ៖ ឯកឧត្តម ថោ សេដ្ឋាណា

អនុរដ្ឋលេខាធិការនិងជាប្រធានក្រុមការងារបច្ចេកទេស
វិមជ្ឈការនិងវិសហមជ្ឈការក្រសួងមុខងារសាធារណៈ

# មាតិកា

១) សង្ខេប

២) សមិទ្ធផលផលសំខាន់ៗនៃការអនុវត្តផែនការសកម្មភាព

៣) បញ្ហាប្រឈម

៤) ទិសដៅបន្ត

៥) សន្និដ្ឋាន

# សទតា

១) ក្រុមការងារបច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការក្រសួងមុខងារសាធារណៈ ត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចលេខ១៤៧៧មស.រប ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៦

២) បេសកកម្មរបស់ក្រុមការងារបច្ចេកទេសនេះត្រូវបានរៀបចំឡើងដោយឈរលើ៖

ក) កម្មវិធីជាតិរយៈពេល ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)

ខ) ផែនការអនុវត្តន៍ ០៣ឆ្នាំ ដំណាក់កាលទី១ (ផអ៣ទី១) ២០១១-២០១៤

គ) ផែនការអនុវត្តន៍ ០៣ឆ្នាំ ដំណាក់កាលទី២ (ផអ៣ទី២) ២០១៥-២០១៧ ត្រូវបានអនុម័តដោយកិច្ចប្រជុំលើកទី១០ របស់គ.ជ.អ.ប (១៩-១២-២០១៤)

# សមិទ្ធផលសំខាន់ៗនៃការអនុវត្តផែនការសកម្មភាព ៖

១) បានផ្សព្វផ្សាយគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ២៥រាជធានី ខេត្ត

២) បានរៀបចំនិងដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៣) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅ២៣រាជធានី ខេត្ត។

៤) សិក្សាស្រាវជ្រាវប្រព័ន្ធគ្រប់គ្រងគុណផលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៥) បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបុគ្គលិកជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតនៅថ្នាក់ក្រោមជាតិ

៦) បានរៀបចំសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

# បញ្ហាប្រឈម

១) ខ្វះខាតឧបករណ៍IT សម្រាប់បំពេញការងារ(ផ្ទុកទិន្នន័យ រួមទាំងការបណ្តុះបណ្តាល)

២) ខ្វះខាតមធ្យោបាយគ្រប់គ្រាន់សម្រាប់ការចុះប្រតិបត្តិការទៅតាមបណ្តាខេត្ត ក្រុង ស្រុក ជាពិសេសចំពោះមុខ ពេលឱ្យចុះផ្សព្វផ្សាយនិងអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការចូលរួមប្រតិបត្តិការលើការផ្ទេរមុខងារ និងធនធានរបស់វិស័យនានាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ទិសដៅបន្ត

១) រៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

២) រៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៣) រៀបចំលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៤) រៀបចំសេចក្តីព្រាងប្រព័ន្ធវាយតម្លៃគុណផលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៥) តាមដាននិងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត ច្បាប់និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក

៦) បន្តចូលរួមរាល់កិច្ចប្រជុំបច្ចេកទេសជាមួយលេខាធិការដ្ឋានNCDD ដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងពេលអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

៧) ចូលរួមក្នុងក្រុមការងារអន្តរក្រសួងសម្រាប់ការផ្ទេរមុខងារនិងធនធានក្នុងវិស័យអប់រំ វិស័យសង្គមកិច្ច និងវិស័យផ្សេងៗទៀតឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# សន្និដ្ឋាន

- ការផ្ទេរមុខងារនិងធនធានបានដើរដល់ដំណាក់កាលមួយ ដែលក្រសួង ស្ថាប័នជាច្រើនពាក់ព័ន្ធនឹងការបម្រើសេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិបានចាប់ផ្តើមផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈ តាមរយៈក្រុមការងារបច្ចេកទេស មានតួនាទីចម្បងនៅក្នុងការរៀបចំលិខិតបទដ្ឋាននានាដើម្បីធានាដល់ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ចាត់ទុកជាប្រវត្តិសាស្ត្រក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ដែលត្រូវការជាចាំបាច់នូវការផ្សព្វផ្សាយដ៏ទូលំទូលាយនៅទូទាំងប្រទេសដើម្បីធានាបាននូវការអនុវត្តដ៏ត្រឹមត្រូវទៅតាមខ្លឹមសារ និងស្មារតីនៃព្រះរាជក្រឹត្យនេះ។ ជាមួយគ្នានេះដែរ ក្រុមការងារត្រូវការជាចាំបាច់នូវការគាំទ្រនិងជួយជ្រោមជ្រែងពីថ្នាក់ដឹកនាំ ដើម្បីសម្រេចបានជោគជ័យនៃការអនុវត្តបេសកកម្មនេះ។

# សូមអរគុណ!